ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

លេខ: ០១០/១៨ រ.ប.ក អ.ជ.ប.គ.ញ

ថ្ងៃសុក្រ ៦កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆមាសទី១ និងទិសដៅការងារ ឆមាសទី២ ឆ្នាំ២០១៨
(ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨)

ឆមាសទី១ឆ្នាំ២០១៨នេះ គឺជាឆ្នាំដែលរាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានបន្តដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ក្នុងគោលបំណងចូលរួមរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ក៏ដូចជាធានាបាននូវភាពកក់ក្តៅជូនប្រជាពលរដ្ឋ និងទប់ស្កាត់រាល់សកម្មភាពអសកម្មនានា នៅមុន ក្នុង និងក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខ ដោយបានប្រមូលផ្តុំសមាសភាពពីគ្រប់មជ្ឈដ្ឋានសង្គម អនុវត្តយ៉ាងសកម្មក្លៀវក្លាបន្ថែមលើការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ តាមរយៈ ការអនុវត្តផែនការយុទ្ធនាការ និងផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀនខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានកត់សម្គាល់ទៅលើសភាពការណ៍គ្រឿងញៀនអន្តរជាតិ ក៏ដូចជាសភាពការណ៍គ្រឿងញៀនជាតិ ព្រមទាំងអនុវត្តការងារទទួលបានលទ្ធផលដូចតទៅ ៖

## I. សភាពការណ៍គ្រឿងញៀន

ក. សភាពការណ៍គ្រឿងញៀនអន្តរជាតិ [1] ៖

ក.១. ការផលិត ៖

បញ្ហាគ្រឿងញៀននៅលើពិភពលោក មិនទាន់មានសញ្ញាថយចុះនៅឡើយទេ ទាំងសកម្មភាពដាំដុះ ផលិត និងចរាចរជួញដូរគ្រឿងញៀន ។ ជាមួយនេះ ក៏មានលេចចេញនូវអង្គការចាត់តាំងឧក្រិដ្ឋកម្មគ្រឿងញៀនថ្មីៗ បន្ថែមទៀត ធ្វើឱ្យទីផ្សារគ្រឿងញៀនខុសច្បាប់មានការកើនឡើង ។ ជាពិសេស គ្រឿងញៀនថ្មី NPS (New Psychoactive Substances) ដែលមានឥទ្ធិពលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រព័ន្ធសរសៃប្រសាទ ហើយពិភពលោកបាន និងកំពុងប្រឈមមុខនឹងការប្រើបំពាន សារធាតុនេះជាច្រើនប្រភេទផងដែរ។

[1] សភាពការណ៍គ្រឿងញៀនអន្តរជាតិ និងក្នុងតំបន់ ដកស្រង់ពីរបាយការណ៍របស់ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ (UNODC)



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

**ក.២. ការប្រើបំពានគ្រឿងញៀន ៖**

អ្នកប្រើបំពានគ្រឿងញៀននៅលើពិភពលោកមានប្រមាណ ១៨៣ លាននាក់ ដែលបានប្រើគ្រឿងញៀនគ្រប់ប្រភេទ ជាពិសេស គ្រឿងញៀនសំយោគ និងប្រភេទ NPS (New Psychoactive Substances) ដែលមានឥទ្ធិពលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រព័ន្ធសរសៃប្រសាទ និងការប្រើគ្រឿងញៀនដោយចាក់ផង ។

**ក.៣. ការបង្ក្រាប និងរឹបអូសគ្រឿងញៀននៅលើពិភពលោក ៖**

គ្រឿងញៀនដែលបង្ក្រាបរៀងរាល់ឆ្នាំមាន កញ្ឆាប្រមាណ ៧.៣១៧តោន, កូកាអ៊ីនប្រមាណ ៨៦៤ តោន, អាភៀនប្រមាណ ៥៨៧ តោន, មេតំហ្វេតាមីនប្រមាណ ១៣២ តោន, ឱសថដែលមានជាតិញៀនប្រមាណ ១១៣ តោន, ហេរ៉ូអ៊ីនប្រមាណ ៩០ តោន, អំហ្វេតាមីនប្រមាណ ៥២ តោន និងអិចស្តាស៊ីប្រមាណ ៦ តោន។

## ខ. សភាពការណ៍គ្រឿងញៀនក្នុងតំបន់ :

**ខ.១. ការផលិត ៖**

គ្រឿងញៀនដែលគេផលិតនៅក្នុងតំបន់ ជាពិសេសបណ្តាប្រទេសនៅក្នុងមហាអនុតំបន់ទន្លេមេគង្គរួមមាន ៖ អាភៀនប្រមាណជាង ៦៥០ តោន, ហេរ៉ូអ៊ីនប្រមាណ ៦០ តោន, មេតំហ្វេតាមីនគ្រាប់ (WY) ប្រមាណ ១.០០០ លានគ្រាប់ និង មេតំហ្វេតាមីនក្រាមម្សៅ (ICE) ប្រមាណ ២០ តោន ក្នុងមួយឆ្នាំៗ ដោយប្រើប្រាស់សារធាតុគីមីផ្សំជាច្រើនពាន់តោន ។ ជាមួយនោះ ការផលិត កេតាមីន, អិចស្តាស៊ី, NPS ក៏មានការកើនឡើងផងដែរ។

ម៉្យាងវិញទៀត គួបផ្សំនឹងសារជាតុគីមីផ្សំ និងសារធាតុគីមីប្រភេទថ្មីផ្សេងៗទៀត ដែលមិនទាន់ស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យក្នុងតារាងសារជាតុគីមីផ្សំនៅឡើយ វាក៏ជាមូលហេតុជំរុញឱ្យមានការផលិតគ្រឿងញៀនច្រើនជាងមុន។

**ខ.២. ការចរាចរ ជួញដូរ ៖**

ក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ ចំនួនឈ្មួញរកស៊ីគ្រឿងញៀននៃក្រុមជនជាតិភាគតិចប្រដាប់អាវុធ និងឈ្មួញជួញដូរគ្រឿងញៀនអន្តរជាតិ ដែលមកពីក្រៅតំបន់មានការកើនឡើង។ អង្គការ UNODC ក៏ដូចជាបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោក បានកត់សម្គាល់ទៅលើការចរាចរគ្រឿងញៀនសំយោគប្រភេទ មេតំហ្វេតាមីនក្រាមម្សៅ(ICE), មេតំហ្វេតាមីនគ្រាប់(WY) និង NPS(New Psychoactive Substances) មានសន្ទុះខ្លាំងក្លាជាងមុនគួរឱ្យព្រួយបារម្ភ ដែលត្រូវបានក្រុមឧក្រិដ្ឋជនធ្វើការចរាចរ ជួញដូរ និងចែកចាយនៅលើទីផ្សារគ្រឿងញៀនពាសពេញតំបន់ និងអន្តរជាតិ ។

## គ. សភាពការណ៍គ្រឿងញៀនកម្ពុជា :

ដោយសារសភាពការណ៍គ្រឿងញៀនដូចខាងលើ ធ្វើឱ្យកម្ពុជានៅតែបន្តទទួលរងផលប៉ះពាល់ពីការចរាចរគ្រឿងញៀនឆ្លងកាត់ពីបណ្តាប្រទេសនានា ទាំងនៅក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ដែលយើងបានធ្វើការកត់សម្គាល់ដូចខាងក្រោម ៖

- ការចរាចរគ្រឿងញៀនឆ្លងកាត់ពីបណ្តាប្រទេសជិតខាង ភាគច្រើនគឺចូលតាមច្រកផ្លូវគោកនៃបណ្តាខេត្តនៅភាគឦសានប្រទេស ដែលបច្ចុប្បន្នការចរាចឆ្លងកាត់តាមច្រកនេះ មិនមានការថយចុះឡើយ
- ការចរាចរគ្រឿងញៀនឆ្លងកាត់ពីតំបន់អាមេរិកខាងត្បូង តំបន់អាហ្វ្រិក តំបន់អឌ្ឍចន្ទមាស ភាគច្រើនគឺធ្វើឡើងតាមផ្លូវអាកាស និងបញ្ញើប្រៃសណីយ៍
- តាមប្រៃសណីយ៍ ក្នុងឆមាសទី១នេះ ក៏មានការដឹកជញ្ជូនជាច្រើនករណី ដែលយើងបានកត់សម្គាល់ឃើញមាន ២ ករណី ដឹកជញ្ជូននូវប្រភេទស្លឹករុក្ខជាតិញៀន ឈ្មោះថា ខាត (KHAT) ពីប្រទេសឥណ្ឌា និង ប៉េរូ ឆ្ពោះទៅ

សហរដ្ឋអាមេរិក ស្របពេលដែលកម្ពុជាបាននិងកំពុងពិនិត្យនិងដាក់បញ្ចូលស្លឹកក្រាតុំនេះ ទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

ជាមួយនឹងការចរាចរគ្រឿងញៀនឆ្លងកាត់ យើងបានកត់សម្គាល់ក្នុងរយៈពេលចុងក្រោយនេះ ការលបលួចដាំដុះដំណាំកញ្ឆា បានកើតមាននៅតាមបណ្តាខេត្តមួយចំនួនផងដែរ ។

## II. អំពីការដឹកនាំ

ក្នុងគោលបំណងចូលរួមរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ធានាបាននូវភាពកក់ក្តៅជូនប្រជាពលរដ្ឋ និងទប់ស្កាត់រាល់សកម្មភាពអសកម្មនានា ក៏ដូចជាការជំរុញអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់តាំងពីថ្នាក់ដឹកនាំកំពូលថ្នាក់ជាតិ ក៏ដូចជាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងថ្នាក់ក្រោមជាតិ បានរៀបចំកម្លាំងនិងចាត់តាំងអនុវត្តដូចខាងក្រោម ៖

### ១. ការដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលគិតគូរដល់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន ៖

- ក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាលើ ព្រះរាជក្រឹត្រ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ផ្ញើសារលិខិតជូនដល់បងប្អូនជនរួមជាតិ នៅក្នុងឱកាសនៃការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ជួបសំណេះសំណាលនិងបញ្ជ្រាបបញ្ហាគ្រឿងញៀននៅក្នុងជួរកម្មករតាមរោងចក្រ សហគ្រាសនានានៅទូទាំងប្រទេសប្រមាណជា **៧០០.០០០** នាក់
- ប្រគល់ការកិច្ចជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ. ក្នុងនាមរាជរដ្ឋាភិបាល ឱ្យបន្តការដឹកនាំអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ដោយប្រមូលផ្តុំសមាសភាពពីគ្រប់មជ្ឈដ្ឋានសង្គម អនុវត្តនូវវិធានការសរុប ប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប ក្នុងការពង្រឹងយន្តការដែលមានស្រាប់ និងរៀបចំយន្តការចាំបាច់បន្ថែម ក៏ដូចជាកសាងផែនការសកម្មភាពមួយចំនួនទៀត ដើម្បីអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ នេះ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវ និងកាន់តែទទួលបាននូវការចូលរួមគាំទ្រពីសាធារណមតិជាតិ និងអន្តរជាតិ ។

### ២. ការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន** ក៏បានណែនាំនូវគោលការណ៍សំខាន់ៗ ក្នុងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ក៏ដូចជាផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទិសដៅការងារដែលបានដាក់ចេញកាលពីឆ្នាំ២០១៧ មានដូចតទៅ ៖

**២.១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវបន្តការអប់រំផ្សព្វផ្សាយ ឱ្យបានកាន់តែសកម្មថែមទៀតដល់គ្រប់សមាសភាពនៅក្នុងសង្គម តាមរយៈបណ្តាញព័ត៌មាន រួមមាន (ប្រព័ន្ធទូរស័ព្ទ ស្ថានីយវិទ្យុ-ទូរទស្សន៍រដ្ឋ ឯកជន ការបិទផ្សាយខ្លឹមសារអប់រំតាមគោលដៅទេសចរណ៍) ការរៀបចំវេទិកាតុមូល វេទិកាសាធារណៈ និងការជួបជាមួយវិស័យឯកជន ។ល។និង។ល។ ឆ្នាំនេះ ត្រូវយកចិត្តទុកដាក់លើក្រុមគោលដៅ

ប្រឈមដែលយើងបានវាយតម្លៃកាលពីឆ្នាំ២០១៧ ថាជាក្រុមគោលដៅដែលពិបាកផ្តល់ការអប់រំ មានដូចជា ក្រុមពលកររចល័ត ពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រ អ្នកបើកបររថយន្តដឹកជញ្ជូន អ្នកបម្រើសេវាកម្សាន្តសប្បាយ សិស្សគេចសាលា ។ល។និង។ល។ ជាមួយនេះ ត្រូវបន្តបណ្តុះបណ្តាលជនបង្គោលឱ្យបានច្រើនបន្ថែមទៀត ដើម្បីពួកគាត់ជួយដល់យើងលើការងារអប់រំផ្សព្វផ្សាយ ។

**២.២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** ជាមួយនឹងការបន្តពង្រឹងសេវាព្យាបាលតាមមូលដ្ឋានសុខាភិបាលសាធារណៈ (មណ្ឌលសុខភាព-មន្ទីរពេទ្យបង្អែក) ត្រូវបន្តពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ-ឯកជន ឱ្យបានរឹងមាំបន្ថែមទៀត ដើម្បីទទួលជនរងគ្រោះដែលទៅទទួលសេវាព្យាបាល ។ ជាមួយនេះ ត្រូវបន្តដំណើរការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី ២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

**២.៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖** ត្រូវបន្តបើកវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ តាមរយៈការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន និងសារធាតុគីមីផ្សំ តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ**(CBT)**, តាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិក( **eLearning)** និងការបណ្តុះបណ្តាលជំនាញផ្សេងៗទៀតដល់មន្ត្រីអនុវត្តច្បាប់គ្រប់ប្រភេទទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ក៏ដូចជាមន្ត្រីបម្រើការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន **(BLO)** ។

**២.៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** ត្រូវបង្កើនការយកចិត្តទុកដាក់គ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំវត្ថុធាតុដើម ព្រមទាំងសារធាតុផ្សំផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ការបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់ និងបន្តរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ស្តីពីការស៊ើបអង្កេត ការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ។ ជាមួយនេះ ត្រូវបន្តការប្រមូលព័ត៌មានពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុញៀនថ្មីដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

**២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** បន្តអនុវត្តនូវរាល់កិច្ចការដែលបានព្រមព្រៀងគ្នាកន្លងមកជាមួយភាគីថៃ ឡាវ និងវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ព្រមទាំងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់ប្រទេសកម្ពុជា ឡាវ និង ថៃ ជាពិសេសត្រូវបន្តការកសាងភូមិ ស គ្មានគ្រឿងញៀននៅតាមព្រំដែន ដែលភាគីកម្ពុជា ឡាវ ថៃ បានឯកភាពគ្នា និងពង្រឹងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន **(BLO)** បន្ថែមទៀត នៅតាមព្រំដែនកម្ពុជា-ឡាវ, កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ។

**២.៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖** បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយអង្គការ( **UNODC**) បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ និងគម្រោងសហប្រតិបត្តិការជាមួយការិយាល័យអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ក៏ដូចជាគម្រោងសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project) ពិសេសការពង្រឹងប្រសិទ្ធភាពការិយាល័យ**(BLO)** ។

**២.៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងរៀបចំផ្សព្វផ្សាយព្រះរាជក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ក្រៅពីការងារដឹកនាំ និងណែនាំនូវគោលការណ៍សំខាន់ៗដូចខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន និងឯកឧត្តម អនុប្រធាន អ.ជ.ប.គ.ញ. បាន ៖

- ជួបជាមួយក្រុមប្រតិភូបច្ចេកទេសរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រថៃ ពាក់ព័ន្ធនឹងការផ្តល់ជំនួយសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន

- បានដឹកនាំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃ២៦ ខែមិថុនា ឆ្នាំ២០១៨ ដោយមានការដុតបំផ្លាញវត្ថុតាងគ្រឿងញៀន (ដូចមាននៅដើមទំព័រទី១០ នៃរបាយការណ៍)។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆមាសទី១ឆ្នាំ២០១៨នេះ យោងតាមផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ក៏ដូចជាការអនុវត្តផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទិសដៅការងារដែលបានដាក់ចេញកាលពីឆ្នាំ២០១៧ យើងបានខិតខំអនុវត្តទទួលបានលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

#### ១.១ ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ÷

គ្រប់ក្រសួង-ស្ថាប័ន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដែលពាក់ព័ន្ធនឹងការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ បានចូលរួមផ្តល់កិច្ចសម្ភាសន៍ជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយ ដូចជា វិទ្យុ-ទូរទស្សន៍រដ្ឋ និងឯកជន, បណ្តាញទូរស័ព្ទចល័ត, គេហទំព័រ។

ដោយឡែក តាមរយៈគេហទំព័រ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានអ្នកចូលអានសរុបប្រមាណ **៤០១.៦០៥** ដង ។

#### ១.២ កម្មវិធីអប់រំផ្សព្វផ្សាយតាមសហគមន៍ ÷

ការងារអប់រំផ្សព្វផ្សាយតាមសហគមន៍ យើងបានរៀបចំកម្មវិធីព្រះពុទ្ធសាសនាផ្សារភ្ជាប់និងសង្គម, កិច្ចប្រជុំ-សិក្ខាសាលា, វេទិកាសាធារណៈ, វេទិកាតុមូល ។ល។និង។ល។ នៅតាមទីវត្តអារាម គ្រឹះស្ថានអប់រំ រោងចក្រ-សហគ្រាស និងធ្វើការចែកចាយខិត្តបណ្ណ័ពាក់ព័ន្ធនឹងការងារបង្ការ ទប់ស្កាត់ការចរាចរ ជួញដូរ រក្សាទុក ប្រើប្រាស់ និងការព្យាបាលអ្នកញៀនគ្រឿងញៀនជាប់ជាប្រចាំ ក្នុងនោះ ៖

**១.២.១.** អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន តាមរយៈ វេទិកាសាធារណៈ កិច្ចប្រជុំនានា មានមហាជនចូលរួម **១២៧.១៦៦** នាក់ ។

**១.២.២.** ក្រសួង-ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ. និងក្រសួង-ស្ថាប័នពាក់ព័ន្ធបាន **៩២.៦៣១** នាក់ ។

**១.២.៣.** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនទាំង ២៥ រាជធានី-ខេត្ត អប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់មន្ត្រីរាជការ សិស្សានុសិស្ស កម្មករតាមរោងចក្រ សហគ្រាស ពលករ ប្រជាពលរដ្ឋទូទាំងប្រទេស តាមរយៈវេទិកាសាធារណៈ វេទិកាតុមូល សរុបបានចំនួន **២.០៨៣.៤០២** នាក់ ។

**១.២.៤.** បណ្តុះបណ្តាលក្រុមជនបង្គោលបាន **៧.៨០២** នាក់ ។

**១.២.៥.** បញ្ជ្រាបការអប់រំពីបញ្ហាគ្រឿងញៀន តាមរយៈការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មប្រមាណ **៨៧.៤០០** នាក់។

សរុបអ្នកបានទទួលសារអប់រំពីបញ្ហាគ្រឿងញៀនមាន **៣.០៩៨.៤០១** អង្គ/នាក់ ធៀប ឆមាសទី១ ឆ្នាំ២០១៧ មាន **៣.៦២៥.១០៧ នាក់** ថយចុះ **៥២៦.៧០៦** នាក់ ស្មើនឹង ១៤,៥២ % ប៉ុន្តែគុណភាពនៃការអប់រំធ្វើបានចំគោលដៅក្រុមងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ និងបណ្តុះបណ្តាលជនបង្គោលបានច្រើន ។

– អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចែកឯកសារផ្សព្វផ្សាយគ្រប់ប្រភេទដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ក្រសួង ស្ថាប័ន រួមមាន ៖

- សៀវភៅច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ២.០០០ ក្បាល
- សៀវភៅចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន ១.៤០០ ក្បាល
- សៀវភៅកម្រងសំណួរ ចម្លើយពីបញ្ហាគ្រឿងញៀន ៧.៥០០ ក្បាល
- ផ្ទាំងរូបភាពខ្នាតតូច ៦.៣០០ សន្លឹក
- ផ្ទាំងរូបភាពខ្នាតធំ ៥.០០០ សន្លឹក
- Sticker ដែល អ.ជ.ប.គ.ញ. សហការផលិតរួមគ្នាជាមួយក្រសួងទេសចរណ៍ ២.០០០ សន្លឹក
- ខិត្តប័ណ្ណផ្សព្វផ្សាយ ១៤.០០០ សន្លឹក

(សរុបរួមមានចំនួន **៣៨.២០០** ក្បាល/សន្លឹក)

– ក្រសួងទេសចរណ៍ ដំឡើងប៉ាណូអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ចំនួន ២០ ផ្ទាំងទៀតពីលើឆ្នាំចាស់ ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់ ÷

ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដែលមានការពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួងសុខាភិបាលជាសេនាធិការ បាន ៖

– បន្តផ្តល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន នៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

– ផ្តល់ការគាំទ្រ និងអនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលចំនួន ២ អនុវត្តបន្តនូវកម្មវិធីម្ជុល/ស៊ីរ៉ាំង។

ជាមួយនេះ អ.ជ.ប.គ.ញ. បានសម្របសម្រួលនិងចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន មន្ត្រីក្រសួង-ស្ថាប័នសមាជិក និងអង្គការដៃគូពាក់ព័ន្ធឱ្យទៅចូលរួមក្នុងកិច្ចប្រជុំ ទាំងនៅក្នុង និងក្រៅប្រទេស សរុប ១៥ លើក មន្ត្រីចូលរួមសរុប **១៧០** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **១៥** នាក់) ។

**កម្មវិធីទាំងនោះ មានជាអាទិ៍ ៖**

– កិច្ចប្រជុំគណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ

– ទិន្នន័យអង្កេតស្រាវជ្រាវចំណេះដឹងស្តីពីជំងឺអេដស៍ ការប្រព្រឹត្តផ្លូវភេទ និងរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនឆ្នាំ២០១៧

– កិច្ចប្រជុំក្រុមប្រឹក្សាយោបល់មជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាប្រឆាំងមេរោគអេដស៍នៅអាស៊ីអាគ្នេយ៍ ។

### ២.២. ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ÷

ឆមាសទី១ ឆ្នាំ២០១៨ នេះ **ចំនួនអ្នកប្រើគ្រឿងញៀនដែលបានធ្វើ បច្ចុប្បន្នភាព** មាន **១៣.៧៤៨** នាក់ ថយចុះ ៦.៧៧៣ នាក់ ស្មើនឹង ៣៣% បើធៀបឆមាសទី១ ឆ្នាំ២០១៧ មាន ២០.៥២១ នាក់ ។ ក្នុងចំនួននេះមាន ៖

– អ្នកប្រើគ្រឿងញៀន ៩.៧២០ នាក់ ស្មើនឹង ៧០,៧០% ដែលកំពុងរស់នៅតាម ឃុំ-សង្កាត់ ក្នុងនោះ ៖

- **អ្នកប្រើគ្រឿងញៀន** ដែលបានសមាហរណកម្មចេញពីមណ្ឌលមាន **៤.១៨១** នាក់ ស្មើនឹង ៤៣,០១%
- **អ្នកប្រើគ្រឿងញៀន** ដែលកំពុងទទួលសេវាព្យាបាលតាមមូលដ្ឋានសុខាភិបាលសាធារណៈ មាន **៣.២៣១** នាក់ ស្មើនឹង ៣៣,២៤%
- **អ្នកប្រើគ្រឿងញៀន** មិនទាន់ទទួលបានការព្យាបាលមាន **២.៣០៨** នាក់ ស្មើនឹង ២៣,៧៤%

– អ្នកប្រើគ្រឿងញៀនដែលកំពុងបន្សាបព្យាបាលនៅតាមមណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋ និងឯកជន ៤.០២៨ នាក់ ស្មើនឹង ២៩,២៩% ។

**បញ្ជាក់ ៖** ក្នុងចំណោមមុខសញ្ញាប្រើប្រាស់គ្រឿងញៀនទាំង **១៣.៧៤៨** នាក់ មាន **១១.៤៤០** នាក់ ស្មើ ៨៣,២១% បាននិងកំពុងទទួលសេវាបន្សាប ព្យាបាល និងស្តារនីតិសម្បទា។

**ជាមួយនោះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន៖**

– ពង្រីកសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ តាមប្រព័ន្ធសុខាភិបាល បាន **៤១៩** កន្លែង ក្នុងនោះ មន្ទីរពេទ្យថ្នាក់ជាតិ ២កន្លែង, មន្ទីរពេទ្យខេត្ត ២៤កន្លែង, មន្ទីរពេទ្យបង្អែក ៧២កន្លែង, មណ្ឌលសុខភាព ៣២១កន្លែង

– ដំឡើងស្លាកសញ្ញាសម្គាល់ទីតាំងផ្តល់សេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន បាន ៣៤៥ ទីតាំង ស្មើនឹង ៨២% លើចំនួនទីតាំងផ្តល់សេវាសរុប

– បន្តការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

### ២.៣. ពង្រឹងសមត្ថភាពលើការងារព្យាបាល និងស្តារនីតិសម្បទា ÷

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួង-ស្ថាប័នពាក់ព័ន្ធជាសេនាធិការបានរៀបចំ៖

– សិក្ខាសាលាស្តីពីសុខភាពផ្លូវចិត្តនិងគ្រឿងញៀន ចំនួន៤វគ្គ ដោយបានប្រមូលផ្តុំ គ្រូពេទ្យ និងគិលានុបដ្ឋាក មកពី ខេត្តព្រះវិហារ បាត់ដំបង ស្ទឹងត្រែង បន្ទាយមានជ័យ ក្រចេះ កំពង់ចាម កណ្តាល កែប កំពត និងខេត្តព្រះសីហនុ មានសិក្ខាកាមចូលរួម ២៣២ នាក់

– សិក្ខាសាលាពិគ្រោះយោបល់ស្តីពីគោលការណ៍ប្រតិបត្តិការ សម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ សិក្ខាកាមចូលរួម ៥១ នាក់

សរុបមានមន្ត្រីចូលរួម **២៨៣** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **១៦** នាក់) ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ៖

អ.ជ.ប.គ.ញ. បានសម្របសម្រួល រៀបចំ និងចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សាដកបទពិសោធន៍ ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេសសរុប **២៤** លើក មានមន្ត្រីចូលរួម **១៨៥** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២៤ នាក់) រួមមាន ៖

– នៅក្នុងប្រទេស ២២ លើក មន្ត្រីចូលរួមសរុប **១៨៣** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន **២២** នាក់)

– នៅក្រៅប្រទេស ២ លើក មន្ត្រីចូលរួមសរុប ២ នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ២ នាក់) ។

**កម្មវិធីទាំងនោះ មានជាអាទិ៍ ៖**

– ការចូលជាសមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

– វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រឿងញៀនតាមប្រព័ន្ធអេឡិចត្រូនិច (e-Learning)

– វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT)

– ទស្សនកិច្ចសិក្សាស្តីពីការរឹបអូសទ្រព្យ និងចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធបទល្មើសគ្រឿងញៀនរបស់ប្រទេសថៃ

– កម្មវិធីត្រួតពិនិត្យកុងតឺន័ររបស់ UNODC នៅតាមកំពង់ផែសមុទ្រ និងបន្តវគ្គបណ្តុះបណ្តាលទ្រឹស្តីនៃការត្រួតពិនិត្យទំនិញតាមផ្លូវអាកាស នៅតាមបណ្តាអាកាសយានដ្ឋានអន្តរជាតិ

- សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) និងការពង្រឹងសមត្ថភាពជាប្រព័ន្ធការិយាល័យទំនាក់ទំនងព្រំដែន (BLO)
- បានបញ្ជូនមន្ត្រីទៅប្រចាំការនៅមជ្ឈមណ្ឌលសម្របសម្រួលទន្លេមេគង្គ នៅប្រទេសចិន
- បានចូលរួមប្រជុំពិនិត្យលើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន [2] ៖

– **បទល្មើសគ្រឿងញៀនសរុប** បង្ក្រាបបាន **៣.៨៣៨** ករណី រួមទាំងបទល្មើសប្រើប្រាស់ ថយចុះ ៤៩៣ ករណី ស្មើនឹង ១១,៣៨ % (បើប្រៀបធៀប ឆមាសទី១ ឆ្នាំ២០១៧ មាន ៤.៣៣១ ករណី) ក្នុងនោះ ៖

- បទល្មើសជួញដូរ **២.៤៧២** ករណី - បទល្មើសដាំដុះកញ្ឆា **១៧** ករណី
- បទល្មើសប្រើប្រាស់ **១.៣៤៨** ករណី - បទល្មើសសំយោគកែច្នៃ **១** ករណី

– **ជនសង្ស័យសរុប** ឃាត់ខ្លួន **៧.៥៨០** នាក់ / ស្រី **៦៧២** នាក់ រួមទាំងបទល្មើសប្រើប្រាស់ ថយចុះ ២.១១៤ នាក់ ស្មើនឹង ២១,៨០ % (បើប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៧ មាន ៩.៦៩៤ នាក់) ។ ក្នុងនោះ ៖

- ជនសង្ស័យជួញដូរ **៤.៤១៧** នាក់ (ស្រី ៤៧៣ នាក់)
- ជនសង្ស័យដាំដុះកញ្ឆា **0** នាក់
- ជនសង្ស័យសំយោគកែច្នៃ **១** នាក់
- អ្នកប្រើប្រាស់គ្រឿងញៀន **៣.១៦២** នាក់ (ស្រី ១៩៩ នាក់) ក្នុងចំនួនអ្នកប្រើប្រាស់ទាំងអស់នោះ យើងបាន ៖
  - ➢ កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ៤៥៤ នាក់
  - ➢ បញ្ជូនទៅមណ្ឌលបន្សាប ព្យាបាល និងស្តារនីតិសម្បទា ១.៧០១ នាក់
  - ➢ អប់រំណែនាំធ្វើកិច្ចសន្យា និងបញ្ជូនឱ្យអាណាព្យាបាលយកទៅបន្សាបព្យាបាលនៅតាមសហគមន៍ ១.០០៧ នាក់។

ក្នុងចំណោមជនសង្ស័យខាងលើ មាន ១៥ សញ្ជាតិ គឺ ៖ ជនជាតិខ្មែរ ៧.៤៤៥ នាក់, វៀតណាម ៩៦ នាក់, ថៃ ១១ នាក់, ឡាវ ៦ នាក់, កូរ៉េ ៤ នាក់, តៃវ៉ាន់ ៣ នាក់, នីហ្សេរីយ៉ា ៣ នាក់, អៀកឡង់ ២ នាក់, បារាំង ២

2 ) បទល្មើស ជនសង្ស័យ វត្ថុតាងគ្រឿងញៀន ទ្រព្យសម្បត្តិ យកតាមតារាងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន

នាក់, ឥណ្ឌូនេស៊ី ២ នាក់, អង់គ្លេស ២ នាក់, អាហ្វ្រិកខាងត្បូង ១ នាក់, អូស្ត្រាលី ១ នាក់, អាមេរិក ១ នាក់, ហ្វីលីពីន ១ នាក់ ។

**គ្រឿងញៀនសំយោគច្រើនប្រភេទ និងកញ្ឆាក្រៀម ចាប់យក សរុប ១៤៥ គ.ក្រ ០១៤ ក្រាម ក្នុងនោះ ÷**

- **គ្រឿងញៀនសំយោគ មាន ១១៩ គ.ក្រ ៣៥០ ក្រាម គឺ ៖**
  - មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៩១ គ.ក្រ ១០៥ ក្រាម
  - មេតំហ្វេតាមីនគ្រាប់ (WY) ១ គ.ក្រ ៨៩៤ ក្រាម
  - អិចស្តាស៊ី ២២ គ.ក្រ ៤៨៣ ក្រាម
  - ហេរ៉ូអ៊ីន ៦១៧ ក្រាម
  - កូកាអ៊ីន ១ គ.ក្រ ៦៩៣ ក្រាម
  - កេតាមីន ១ គ.ក្រ ៥៥៨ ក្រាម
- **រុក្ខជាតិញៀន ៖**
  - កញ្ឆាក្រៀម ២៥ គ.ក្រ ៦៦៤ ក្រាម
  - ដើមកញ្ឆា ១២៥.៣៤៣ ដើម
  - ស្លឹកខាត ៣.២៣៧ គ.ក្រ ៣៦០ ក្រាម **(មិនបានបូកបញ្ចូលទេ ព្រោះមិនទាន់មានក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់)**

- ទ្រព្យសម្បត្តិសំខាន់ៗ ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត រួមមាន រថយន្ត ៤៥ គ្រឿង, ម៉ូតូ ១.០៥១ គ្រឿង, ប្រាក់កម្ពុជា ២៥.៤៦៣.៣០០ រៀល, ប្រាក់អាមេរិក ៣.៥៣៦ ដុល្លារ, ប្រាក់ថៃ ១៦.០៥០ បាត, ប្រាក់វៀតណាម ២.៥២១.០០០ ដុង, ប្រាក់ចិន ២៤.០០០ យុន ។

- ជនសង្ស័យ ចាប់ខ្លួនតាមដីកា មាន ១២៩ ដីកា ឃាត់ខ្លួនជនសង្ស័យ ១២៥ នាក់ (ស្រី ៦ នាក់) ។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល ៖

– បានចុះអប់រំម្ចាស់ទីតាំងសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ភោជនីយដ្ឋាន ខារ៉ាអូខេ សរុប ២៧១ កន្លែង

– បានអញ្ជើញម្ចាស់ទីតាំងសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ភោជនីយដ្ឋាន ខារ៉ាអូខេ មកចូលរួមប្រជុំបាន ៧៤៩ នាក់

– បានធ្វើតេស្តរកសារធាតុញៀនក្នុងទឹកនោមបាន ១.៧៣៣ នាក់ និងរកឃើញអ្នកមានតម្រុយផ្ទុកសារធាតុញៀន ចំនួន ៤០៨ នាក់ ។

### ៣.៤. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ៖

មន្ទីរពិសោធន៍គ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀនបាន **១.៩៥១** សំណាក = **១.៨៣៩** ករណី ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន ១.៨៨២** សំណាក (៩៦,៤៦%) = **១.៨០០** ករណី គឺ ៖
  - មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១.៧៤២ សំណាក (៨៩,២៨ %)
  - មេតំហ្វេតាមីនគ្រាប់ (WY) ៦៣ សំណាក (៣,២២ %) - កូកាអ៊ីន ១១ សំណាក (០,៥៦%)
  - ហេរ៉ូអ៊ីន ១ សំណាក (០,០៥%) - កេតាមីន ១៦ សំណាក (០,៨២ %)
  - MDMA ៣៥ សំណាក (១,៧៩ %) - នីមេតាហ្សេប៉ាម ៦ សំណាក (០,៣០ %)
  - កញ្ឆា ៨ សំណាក (០,៤១ %)

- ***សំណាកអវិជ្ជមានសារធាតុញៀន ៦៩*** សំណាក = **៣៩** ករណី (៣,៥៣%)

ក្រៅពីការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន មន្ទីរពិសោធន៍របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បាន ៖

- ដុតបំផ្លាញវត្ថុតាងគ្រឿងញៀនជាច្រើនប្រភេទប្រមាណជិត **៦៤** គីឡូក្រាម នៅក្នុងឱកាសនៃការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ផ្តល់ដល់ស្ថាប័នអនុវត្តច្បាប់ រួមមាន ៖ អគ្គស្នងការដ្ឋាននគបាលជាតិ អគ្គនាយកដ្ឋានពន្ធនាគារ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត មន្ទីរប្រឆាំងគ្រឿងញៀន ស្នងការដ្ឋាននគបាល-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត កងទ័ពជើងទឹក កងពលតូចលេខ៧០ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវ ៖

  - ស្រោមវេចខ្ចប់សំណាកសង្ស័យជាគ្រឿងញៀន សរុបចំនួន ១.៣៥០ សន្លឹក
  - ម៉ាគ្គីតេស្ត ៤.១៣០ តេស្ត - កេតាមីនតេស្ត ២២០ តេស្ត - កូកាអ៊ីន ៤០ តេស្ត - ឆិនការ ៦០ តេស្ត - ស្កត់តេស្ត ២៨១ តេស្ត - ម៉ាគ្គីដប ៩០០ មិល្លីលីត្រ - ស៊ីម៉ុនដប ៦០០ មិល្លីលីត្រ - តេស្តរកសារធាតុញៀនក្នុងទឹកនោម ២១.៤៣៥ តេស្ត ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

**៤.១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការតាមដាន ត្រួតពិនិត្យសារធាតុគីមីផ្សំ ដែលមាននៅក្នុងតារាងដូចខាងក្រោមគឺ ៖

- **តារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ក្នុងឆមាសទី១ ឆ្នាំ២០១៨នេះ សរុបមាន **៣.០៣២.១១៥ គ.ក្រ** និង **១៥៥ លីត្រ** ក្នុងនោះ ៖
  - ក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានផ្តល់អាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់មុខសញ្ញាស្តង់ដារប្រើប្រាស់សារធាតុគីមី ចំនួន ២.៣៨៩.០៣៥ គ.ក្រ និង ១៥២ លីត្រ
  - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្តល់អាជ្ញាប័ណ្ណ ចំនួន ៦៤៣.០៨០ គ.ក្រ និង ៣ លីត្រ
- **តារាងឧបសម្ព័ន្ធទី២ និងទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន** ដែលមានអាជ្ញាប័ណ្ណរបស់ក្រសួងសុខាភិបាល ក្នុងទម្រង់ជាវត្ថុធាតុដើមចំនួន ១០០ គ.ក្រ និងទម្រង់ជាឱសថ មាន ១០ គ.ក្រ ។

**៤.២.** បានរៀបចំកិច្ចប្រជុំក្រុមលេខា នៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

បានចូលរួមនិងសហការសម្របសម្រួល អនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយប្រទេសថៃ ឡាវ និង វៀតណាម ទាំងនៅក្នុង និងនៅក្រៅប្រទេសសរុប **១៥** លើក មានមន្ត្រីចូលរួម **២៥** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. **១៥** នាក់)។ ក្នុងនោះ ៖

- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំក្រុមការងារចុះទៅ ៖
  - ពង្រឹងការអនុវត្តផែនការ "ភូមិសគ្មានគ្រឿងញៀន" និងបានប្រគល់សម្ភារសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន២កន្លែង និង"ភូមិសគ្មានគ្រឿងញៀន" ចំនួន៣ភូមិ ជូនដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះវិហារ
  - ប្រគល់សម្ភារសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន៣កន្លែង និង "ភូមិសគ្មានគ្រឿងញៀន" ចំនួន២ភូមិ ជូនដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តស្ទឹងត្រែង។

(សម្ភារទាំងនោះ ជាជំនួយនៃគម្រោងសុវត្ថិភាពទន្លេមេគង្គនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និង កម្ពុជា-ឡាវ)

- ទស្សនកិច្ចសិក្សា ស្តីពីការរឹបអូស និងការចាត់ចែងទ្រព្យសម្បត្តិ ដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន របស់ប្រទេសថៃ ដើម្បីដកស្រង់បទពិសោធន៍សម្រាប់ប្រតិភូនៃគណៈកម្មការ ការតាមដាន ការប្រមូលការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

បានចូលរួម និងសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ក្នុងក្របខ័ណ្ឌអនុតំបន់ តំបន់ អន្តរជាតិ ដូចជា សន្និសីទ វេទិកាសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន អន្តរជាតិ កិច្ចប្រជុំប្រចាំឆ្នាំ ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ សិក្ខាសាលា និងទស្សនកិច្ចសិក្សានៅក្រៅប្រទេស សរុប **១៦** លើក មន្ត្រីចូលរួមសរុប **៥៩** នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. **៣៤** នាក់ ។

**កម្មវិធីទាំងនោះ ជាអាទិ៍ ៖**

- កិច្ចប្រជុំស្តីពីប្រតិបត្តិការតំបន់ត្រីកោណមាស ក្រោមផែនការកិច្ចសហប្រតិបត្តិការ៣ឆ្នាំ សម្រាប់គម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ
- វគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដោយមានការចាត់តាំង
- សន្និសីទស្តីពីកិច្ចប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន (ADEC-23) លើកទី១៣ នៅតំបន់អាស៊ី ប៉ាស៊ីហ្វិក
- សិក្ខាសាលាអាស៊ានស្តីពី កិច្ចប្រតិបត្តិការបណ្តាញឃ្លាំមើលគ្រឿងញៀន លើកទី៥
- កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ (GBC) លើកទី១៣
- សិក្ខាសាលាអាស៊ានស្តីពីការងារស្ថិតិជំណាំគ្រឿងញៀនក្រោមគម្រោង ASEAN NARCO
- មហាសន្និបាតស្តីពីនិរន្តរភាពនៃការអភិវឌ្ឍ ការបង្ការបទឧក្រិដ្ឋទាក់ទងការដាំដុះដំណាំគ្រឿងញៀន
- កិច្ចប្រជុំគណៈកម្មាធិការគ្រឿងញៀន លើកទី៦១
- សិក្ខាសាលាអាស៊ានស្តីពីការវិភាគផ្លូវចរាចរគ្រឿងញៀន និងសារធាតុគីមីផ្សំតាមដងទន្លេមេគង្គ
- វគ្គបណ្តុះបណ្តាលការអនុវត្តជាក់ស្តែងស្តីពីការចែកចេរ ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស នៃកម្មវិធីត្រួតពិនិត្យកុងតឺន័រ
- វគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេត និងលុបបំបាត់ឧក្រិដ្ឋកម្មគ្រឿងញៀន ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ របស់រាជរដ្ឋាភិបាល អ.ជ.ប.គ.ញ. បានពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈ ៖

**៧.១.** ការបន្តដឹកនាំគណៈកម្មការទាំង៦ និងអនុគណៈកម្មការទាំង៣ នៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ព្រមទាំងរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តផែនការនេះ ។

**៧.២.** ការដឹកនាំអនុវត្តផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២០១៦-២០១៨) ។

**៧.៣.** ការដឹកនាំអនុវត្តតាមទិសដៅការងារដែលបានដាក់ចេញកាលពីឆ្នាំ២០១៧ ។

**៧.៤.** បាននិងកំពុងរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៧.៥.** ការប្រជុំក្រុមលេខា នៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ។

**៧.៦.** បាននិងកំពុងបន្តការផ្សព្វផ្សាយព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**៧.៧.** បាននិងកំពុងរៀបចំនីតិវិធីដាក់បញ្ចូលស្លឹករុក្ខជាតិខាត (KHAT) ទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់

ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## IV. ការសន្និដ្ឋាន និងវាយតម្លៃ

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖

**ចំណុចខ្លាំង ៖**

បើទោះបីជាចំនួនអ្នកបានទទួលការអប់រំមានការថយចុះជាង ឆមាសទី១ ឆ្នាំ២០១៧ ក៏ពិតមែន ប៉ុន្តែការអប់រំនៅក្នុង ឆមាសទី១ ឆ្នាំ២០១៨ មានលក្ខណៈច្បាស់លាស់ជាង ដោយសារយើង ៖

– បានរៀបចំឱ្យមានផែនការសកម្មភាពជាក់លាក់ និងមានលក្ខណៈពហុវិស័យ ដោយបានកំណត់នូវក្រុមគោលដៅ និងបែងចែកការទទួលខុសត្រូវច្បាស់លាស់ដល់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដើម្បីធានាថាគ្រប់ក្រុមគោលដៅងាយប្រឈមខ្ពស់នឹងគ្រោះ បានទទួលសារឬការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន

– ផ្អែកទៅលើផែនការសកម្មភាពដែលបានកំណត់ ក្រសួង-ស្ថាប័ន អង្គភាព ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនពីថ្នាក់រាជធានី-ខេត្ត រហូតដល់ថ្នាក់មូលដ្ឋានឃុំ-សង្កាត់ ភាគច្រើនបានយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់

– ជនបង្គោលរបស់ក្រសួង-ស្ថាប័ន ដែលបានបណ្តុះបណ្តាល ពួកគាត់បានចូលរួមធ្វើសកម្មភាពផ្សព្វផ្សាយអប់រំជាមួយយើងយ៉ាងផុលផុស

– ទទួលបានការចូលរួម និងគាំទ្រកាន់តែច្រើនឡើងៗពីគ្រប់សមាសភាពសង្គម ពិសេសការចូលរួម និងគាំទ្រពីស្ថាប័នជាតិសំខាន់ៗ ដូចជាព្រឹទ្ធសភា រដ្ឋសភា កាកបាទក្រហមកម្ពុជា ក៏ដូចជាការចូលរួមនិងគាំទ្រពីវិស័យសាសនា វិស័យឯកជន មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ លោកគ្រូ-អ្នកគ្រូ និស្សិត សិស្សានុសិស្ស ប្រព័ន្ធផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍ ប្រព័ន្ធទំនាក់ទំនងសង្គម រួមផ្សំជាមួយនឹងការចូលរួម និងគាំទ្រកាន់តែសកម្ម និងផុលផុសរបស់ប្រជាពលរដ្ឋ ធ្វើឱ្យការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនកាន់តែមានភាពងាយស្រួល និងកាន់តែស៊ីជម្រៅ ។

**ចំណុចខ្វះខាត ៖**

– ក្រសួង-ស្ថាប័ន ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តមួយចំនួនតូច នៅតែមិនទាន់បានយកចិត្តទុកដាក់ឱ្យអស់ពីលទ្ធភាព និងទទួលខុសត្រូវអនុវត្តឱ្យបានសកម្មនូវរាល់ភារកិច្ចដែលបានកំណត់ និងបែងចែកក្នុងផែនការសកម្មភាព

– ក្រសួង-ស្ថាប័ន ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តខ្លះទៀត បានចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធទាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ បានសកម្មហើយ ប៉ុន្តែមិនបានធ្វើរបាយការណ៍មកលេខាធិការដ្ឋាននៃផែនការយុទ្ធនាការឱ្យបានទៀងទាត់

– ក្រុមគោលដៅប្រឈមខ្លះទៀត ដូចជាក្រុមពលករចល័ត ឬពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រ អ្នកបើកបរយានយន្តដឹកជញ្ជូន អ្នកបម្រើសេវាកម្សាន្តសប្បាយ សិស្សគេចសាលា នៅតែជាក្រុមគោលដៅដែលទទួលបានការអប់រំផ្សព្វផ្សាយតិចជាងគេ

– ការបិទផ្សាយសារអប់រំពីបញ្ហាគ្រឿងញៀននៅលើផលិតផល នៅតែមិនទាន់មានលក្ខណៈទូលំទូលាយ

– ជនបង្គោលដែលបានបណ្តុះបណ្តាលហើយ ភាគច្រើនសមត្ថភាពរបស់ពួកគាត់នៅមានកម្រិត

– រដ្ឋបាលមូលដ្ឋានឃុំ-សង្កាត់ ក៏ដូចជាប៉ុស្តិ៍នគរបាលរដ្ឋបាលមួយចំនួន នៅតែមិនទាន់ទទួលខុសត្រូវដើរតួជាកម្លាំងជួរមុខក្នុងការបង្ការ ទប់ស្កាត់ និងដោះស្រាយរាល់បញ្ហា ដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន នៅក្នុងមូលដ្ឋានរបស់ខ្លួន ហើយភាគច្រើនពឹងផ្អែកទៅលើកិច្ចអន្តរាគមន៍ពីសមត្ថកិច្ចថ្នាក់លើ ។

២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖

**ចំណុចខ្លាំង ៖**

ចំនួនអ្នកប្រើប្រាស់គ្រឿងញៀនមានការថយចុះ បើធៀបឆមាសទី១ ឆ្នាំ២០១៧ អាស្រ័យដោយ ៖

– គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បានពង្រឹងនិងពង្រីកការងារព្យាបាល និងលើកកម្ពស់សមត្ថភាពមន្ត្រីរបស់ខ្លួនពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន

– កិច្ចសហការកាន់តែប្រសើររវាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ពិសេសកិច្ចសហការល្អរវាងអង្គភាពអនុវត្តច្បាប់ ព្រះរាជអាជ្ញា តុលាការ និង អង្គភាពផ្តល់សេវាសុខភាព

– ការកើនឡើងនូវការយល់ដឹង និងភ្ញាក់រលឹករបស់ប្រជាពលរដ្ឋ ក្នុងការបញ្ជូនកូនចៅដែលប្រើប្រាស់ ឬញៀនគ្រឿងញៀនឱ្យទៅទទួលយកសេវាព្យាបាល និងស្តារនីតិសម្បទា ។

**ចំណុចខ្វះខាត ៖**

– នៅមានអ្នកប្រើ និងអ្នកញៀនគ្រឿងញៀនប្រមាណ ៤០% មិនទាន់បានទៅទទួលការព្យាបាល និងស្តារនីតិសម្បទា ដែលបញ្ហានេះអាចបណ្តាលមកពីការខ្លាចរអារចំពោះការអនុវត្តច្បាប់ ឬការមិនយល់ដឹងច្បាស់លាស់ពីការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទា

– យន្តការ និងសេវាគាំទ្រក្នុងដំណាក់កាលនៃការធ្វើសមាហរណកម្ម ដូចជាការបណ្តុះបណ្តាលបំណិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ពួកគាត់នៅមិនទាន់ឆ្លើយតបបានតាមតម្រូវការទីផ្សារការងារ

– ការតាមដាន និងវាយតម្លៃលើការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនទាំងនៅតាមមណ្ឌលបណ្តោះអាសន្ន និងនៅតាមសហគមន៍ ធ្វើមិនទាន់បានទៀងទាត់ និងច្បាស់លាស់

– ការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀនដែលជាពិរុទ្ធជន-ទណ្ឌិតនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនៅតែមិនទាន់ដំណើរការបានល្អ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖**

**ចំណុចខ្លាំង ៖**

មន្ត្រីអនុវត្តច្បាប់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទទួលបាននូវការគាំទ្រជាថវិកា និងការសរសើរលើកទឹកចិត្តតាមគ្រប់រូបភាព ពីគណៈដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងព្រមទាំងការបណ្តុះបណ្តាលជាបន្តបន្ទាប់ គួបផ្សំនឹងការអនុវត្តជាក់ស្តែង រួមជាមួយការប្រើប្រាស់កម្លាំងសរុប ធ្វើឱ្យការស្រាវជ្រាវ ស៊ើបអង្កេតបទល្មើសកាន់តែមានប្រសិទ្ធភាព ។ ជាមួយនេះ តាមរយៈកិច្ចសហការផ្តល់ព័ត៌មានរហ័សឱ្យគ្នាទៅវិញទៅមកជាមួយប្រទេសជិតខាង និងស្ថាប័នអន្តរជាតិបានល្អ និងធ្វើឱ្យការទប់ស្កាត់និងបង្ក្រាបបទល្មើសបានច្រើនករណីធំៗ ។ តាមរយៈ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣នេះ បានធ្វើឱ្យជះឥទ្ធិពលដល់បទល្មើសផ្សេងៗ ជាពិសេសបទល្មើសព្រហ្មទណ្ឌមានការថយចុះ ។

**បញ្ហាប្រឈម ៖**

–ឧក្រិដ្ឋជនអន្តរជាតិ នៅតែព្យាយាមប៉ុនប៉ងប្រើប្រាស់កម្ពុជា ធ្វើជាប្រទេសផលិតកែច្នៃ និងឆ្លងកាត់គ្រឿងញៀនខុសច្បាប់ តាមគ្រប់រូបភាព ទាំងផ្លូវគោក ផ្លូវទឹក អាកាស និងប្រៃសណីយ៍

–ឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិបានបោះទុនយ៉ាងច្រើនទៅឱ្យតំបន់ត្រីកោណមាស ដើម្បីផលិតគ្រឿងញៀនសម្រាប់ធ្វើការចែកចាយនៅទូទាំងតំបន់

–ដោយសារនៅក្នុងអនុតំបន់ មានប្រទេសខ្លះបានផ្លាស់ប្តូរគោលនយោបាយជាតិរបស់គេ បានជំរុញឱ្យអតីត

ក្រុមជនជាតិភាគតិច និងក្រុមថ្មីផ្សេងទៀត ដែលទើបកើតឡើងបាននាំគ្នាផលិតគ្រឿងញៀន ដើម្បីលក់យកប្រាក់សម្រាប់មូលនិធិនិងសេចក្តីត្រូវការរបស់ក្រុមខ្លួន។

–បណ្តាខេត្តនៅភាគឦសានប្រទេស នៅតែជាខេត្តដែលបន្តមានសកម្មភាពលួចចរាចរនាំចូលគ្រឿងញៀនដោយខុសច្បាប់ ទោះបីយើងបង្ក្រាបបានចំករណីធំៗ និងកាត់ផ្តាច់ខ្សែរយៈទាក់ទងជាច្រើនហើយក៏ដោយ ។

**ចំណុចខ្វះខាត ៖**

–មកដល់ពេលនេះ យើងបណ្តុះបណ្តាលជំនាញដល់មន្ត្រីអនុវត្តច្បាប់ នៅថ្នាក់ក្រោមជាតិបានច្រើន ប៉ុន្តែនីតិវិធីនៃការចោទប្រកាន់នៅមិនទាន់រឹងមាំ

–ម្ចាស់ទីតាំងផ្ទះសំណាក់ ផ្ទះជួល អាជីវកម្ម សេវាកម្មកម្សាន្តមួយចំនួន នៅមិនទាន់បានរាយការណ៍ ឬមិនសហការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនដល់សមត្ថកិច្ច ឬផ្តល់ព័ត៌មានមកសមត្ថកិច្ចយឺតយ៉ាវ មួយចំនួនទៀតឆ្លៀតឱកាសនេះ ឃុបឃិតទាញយកផលប្រយោជន៍ពីជនល្មើស ពីអ្នកប្រើប្រាស់ តាមរូបភាពផ្សេងៗគ្នា ។

–មធ្យោបាយ សម្ភារ សម្រាប់បម្រើឱ្យកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀននៅតែជាបញ្ហាចោទ ចំពោះមុខដែលត្រូវដោះស្រាយ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

**ចំណុចខ្លាំង ៖**

ដោយមានកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ យើងគ្រប់គ្រងបានជាប់ជាប្រចាំនូវទិន្នន័យសារធាតុគីមីផ្សំដែលមានការអនុញ្ញាតឱ្យនាំចូល ។ តាមរយៈការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តច្បាប់យើង កាន់តែមានបទពិសោធន៍ក្នុងការបង្ការ ទប់ស្កាត់បានការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់យកទៅសំយោគផលិតជាគ្រឿងញៀនខុសច្បាប់ ។

**ចំណុចខ្វះខាត ៖**

–យន្តការការងាររបស់ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ មិនទាន់ដំណើរការពេញលេញ

–ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំដល់សមត្ថកិច្ចពាក់ព័ន្ធ និងបុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី នៅមិនទាន់ធ្វើបានទូលំទូលាយនៅឡើយ

–នៅមិនទាន់មានការត្រួតពិនិត្យបានច្បាស់លាស់ពីការចរាចរ ការប្រើប្រាស់ និងសន្និធិសារធាតុគីមីផ្សំ ដែលប្រើប្រាស់ដោយសិប្បកម្មក្នុងស្រុកនានា ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

**ចំណុចខ្លាំង ៖**

កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងយន្តការ នៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន តាមរយៈ ការជួយបណ្តុះបណ្តាលជំនាញដល់មន្ត្រីអនុវត្តច្បាប់នៅទូទាំងប្រទេស ការផ្តល់មធ្យោបាយ និងសម្ភារ បរិក្ខារចាំបាច់មួយចំនួនជួយសម្រួលដល់សេចក្តីត្រូវការចំពោះមុខ និងការផ្តល់ថវិកា ដើម្បីទ្រទ្រង់សកម្មភាពអាទិភាពត្រួតពិនិត្យគ្រឿងញៀន។ យន្តការនៃការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកទាក់ទងនឹងបទល្មើសគ្រឿងញៀន ដើម្បីឈានទៅដល់ការទប់ស្កាត់ និងបង្ក្រាបទាន់ពេលនូវករណីជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែន កាន់តែត្រូវបានលើកកម្ពស់និងសកម្មជាងមុន។ ជាងនេះទៅទៀតយើងបានឯកភាពគ្នារៀបចំកសាង "ភូមិស គ្មានគ្រឿងញៀន" នៅតំបន់ព្រំដែនកម្ពុជា-ឡាវ / កម្ពុជា-ថៃ រួមទាំងការបង្កើតបន្ថែមនូវការិយាល័យទាក់ទំនងព្រំដែន (BLO) ។

**ចំណុចខ្វះខាត ៖**

ទោះបីជាយើងបានសហការជាមួយប្រទេសជិតខាងទទួលបានលទ្ធផលជាច្រើនក៏ពិតមែន ប៉ុន្តែករណីប្រើប្រាស់គ្រឿងញៀននៅតាមតំបន់ព្រំដែន និងបទល្មើសជួញដូរគ្រឿងញៀនខុសច្បាប់ឆ្លងកាត់ព្រំដែន នៅតែកើតមានឡើង ដែលតម្រូវឱ្យយើងយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងក្លាថែមទៀត។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖**

**ចំណុចខ្លាំង ៖**

កម្ពុជាបានពង្រឹង និងពង្រីកសមត្ថភាពត្រួតពិនិត្យគ្រឿងញៀនរបស់ខ្លួនជាប់ជាប្រចាំ ដោយបានចូលរួមយ៉ាងសកម្មជាមួយយន្តការត្រួតពិនិត្យគ្រឿងញៀនទាំងក្នុងក្របខ័ណ្ឌ អនុតំបន់ តំបន់ និងអន្តរជាតិ និងទទួលបាននូវកិច្ចសហប្រតិបត្តិការល្អពីប្រទេសដៃគូ ក្នុងការទប់ស្កាត់ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសគ្រឿងញៀន ដែលក្រុមឧក្រិដ្ឋជនប៉ុនប៉ងយកប្រទេសកម្ពុជា ធ្វើជាកន្លែងផ្លាស់ប្តូរវេចខ្ចប់គ្រឿងញៀន ដើម្បីនាំចេញទៅប្រទេសទី៣។

**ចំណុចខ្វះខាត ៖**

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការជួយគាំទ្រជាថវិកា មធ្យោបាយ និងសម្ភារ ពីបណ្តាប្រទេសផ្តល់ជំនួយក៏ដូចជាដៃគូអភិវឌ្ឍន៍នានា លើសកម្មភាពត្រួតពិនិត្យគ្រឿងញៀន បានកាត់បន្ថយមកនៅក្នុងកម្រិតតិចតួចបំផុត ដែលទាំងអស់នេះបានជះឥទ្ធិពលមិនល្អដល់សកម្មភាពត្រួតពិនិត្យគ្រឿងញៀនទាំងនៅកម្ពុជា និងក្នុងតំបន់។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖**

**ចំណុចខ្លាំង ៖**

– ការបន្តដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបន្តពុះពារលុបបំបាត់គ្រឿងញៀននៅកម្ពុជា ដោយទទួលបាននូវការគាំទ្រ និងវាយតម្លៃខ្ពស់ពីគ្រប់មជ្ឈដ្ឋាន

– យន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានស្រាប់បានដំណើរការងារប្រកបដោយឆន្ទៈមោះមុត និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការចាត់តាំងដឹកនាំអនុវត្តផែនការសកម្មភាពទៅតាមសមត្ថកិច្ចរៀងៗខ្លួន ជាពិសេសការអនុវត្តនូវវិធានការទាំង**៥** នៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន ធ្វើឱ្យទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់។

**ចំណុចខ្វះខាត ៖**

–យន្តការត្រួតពិនិត្យគ្រឿងញៀនរបស់រាជធានី-ខេត្តមួយចំនួន អនុវត្តមិនទាន់បានជាលក្ខណៈពហុវិស័យ

–បានបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនដល់ថ្នាក់សង្កាត់-ឃុំរួចហើយ តែសកម្មភាពការងារមិនទាន់អនុវត្តបានជាប្រចាំ, មិនទាន់បានរៀបចំយន្តការ និងជំរុញលើកទឹកចិត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនស្របតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

– តាមរយៈ ការអនុវត្តច្បាប់កន្លងមក ទាមទារត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលត្រូវការរយៈពេលមួយយូរបង្គួរ។

## V. ផែនការសកម្មភាពអនុវត្តទិសដៅការងារ ឆមាសទី២ ឆ្នាំ២០១៨

ផ្អែកលើការសន្និដ្ឋានវាយតម្លៃ និងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវទិសដៅសម្រាប់អនុវត្តក្នុង ឆមាសទី២ ឆ្នាំ២០១៨ ដូចខាងក្រោម ៖

**១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖**

**១.១.** បន្តការអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាព (បណ្តាញព័ត៌មាន ប្រព័ន្ធទូរស័ព្ទ ស្ថានីយវិទ្យុ ទូរទស្សន៍រដ្ឋ-ឯកជន ការបិទផ្សាយខ្លឹមសារអប់រំតាមគោលដៅទេសចរណ៍) ឱ្យបានគ្រប់ទីកន្លែង គ្រប់ពេលវេលាជាប់ជាប្រចាំ និងឱ្យបានចំគោលដៅប្រឈម និងក្រុមដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ដូចជា ក្រុមពលករចល័ត ពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រ អ្នកបើកបររថយន្តដឹកជញ្ជូន អ្នកបម្រើសេវាកម្សាន្តសប្បាយ សិស្សគេចសាលា ។ល។និង។ល។

**១.២.** បន្តការបណ្តុះបណ្តាលក្រុមជនបង្គោលនៅតាមក្រសួង-ស្ថាប័ន ជាពិសេសខិតខំពង្រឹងរដ្ឋបាលមូលដ្ឋានឃុំ-សង្កាត់ នគរបាលរដ្ឋបាល ឱ្យចូលរួមជាកម្លាំងជួរមុខក្នុងការងារអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងជំរុញរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន នៅក្នុងមូលដ្ឋានរបស់ខ្លួន ។

**១.៣.** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ត្រូវបន្តអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព តាមរយៈ ការរៀបចំវេទិកាសាធារណៈ វេទិកាតុមូល វេទិកាជួបជាមួយវិស័យឯកជន ដើម្បីក្តាប់បានពីគោលបំណង សំណូមពរ និងមានដំណោះស្រាយជូនប្រជាជនឱ្យបានទាន់ពេលវេលា ។

**១.៤.** បន្តធ្វើបច្ចុប្បន្នភាពលើខ្លឹមសារឯកសារអប់រំ ផ្សព្វផ្សាយ ដើម្បីឱ្យមានភាពទាក់ទាញ និងចាប់អារម្មណ៍ពីមហាជនទូទៅ ក៏ដូចជាដល់ក្រុមជនគោលដៅងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ដោយការប្រើប្រាស់គ្រឿងញៀន ។

**១.៥.** បន្តចលនា លើកទឹកចិត្តដល់អាណាព្យាបាល ក៏ដូចជាវិស័យឯកជន ក្នុងការចូលរួមលើការងារអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀន ។

**១.៦.** បន្តការចងក្រងយន្តការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធ ការអប់រំសីលធម៌បដិសេធគ្រឿងញៀន នៅតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត ។ ជាមួយនេះ ត្រូវបន្តជំរុញ លើកទឹកចិត្តគ្រូបង្រៀន សិស្ស និស្សិត និងគរុសិស្សចូលរួមបង្ការ ទប់ស្កាត់ និងលុបបំបាត់គ្រឿងញៀននៅក្នុងសង្គម តាមរូបភាពសិល្បៈអប់រំ ដូចជាគូរគំនូរ តែងចម្រៀង តែងកំណាព្យ លេងកីឡា និង សិល្បៈ ។ល។ និង ។ល។

**១.៧.** បន្តលើកទឹកចិត្តដល់អតីតអ្នកញៀនគ្រឿងញៀន និងក្រុមគ្រួសារដែលបានចាកចេញពីគ្រឿងញៀន ដើម្បីឱ្យពួកគេចូលរួមក្នុងការអប់រំមហាជនឱ្យចេះបដិសេធគ្រឿងញៀន។

**១.៨.** បន្តចលនាឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អង្គការសាសនា វិស័យឯកជន សំដៅកាត់បន្ថយតម្រូវការគ្រឿងញៀន តាមគ្រប់រូបភាព គ្រប់ពេលវេលា គ្រប់ទីកន្លែង ។

**១.៩.** បន្តជំរុញ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងគណកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត លើការងារផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនជាមួយវិស័យឯកជន និងក្រុមហ៊ុន ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖**

**២.១.** បន្តការងារសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

**២.២.** បន្តពង្រឹងគុណភាព សមត្ថភាព មណ្ឌលបណ្តោះអាសន្នរបស់រដ្ឋសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ (មន្ទីរពេទ្យបង្អែក-មណ្ឌលសុខភាព) ដោយមានយន្តការដាក់លាក់ទៅលើខ្លឹមសារបីគឺ ៖ ការព្យាបាល

ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើសមាហរណកម្ម ព្រមទាំងជំរុញការអនុវត្តនូវវិធានការគាំទ្រ លើកទឹកចិត្ត រដ្ឋបាល និងវិធានការច្បាប់ ។

**២.៣.** បន្តចលនាឱ្យមានការចូលរួមពីគ្រប់បុគ្គលនិងអង្គភាព ចូលរួមបំផុស និងលើកទឹកចិត្តឱ្យអ្នកញៀនគ្រឿងញៀនទៅទទួលយកសេវាព្យាបាលដោយស្ម័គ្រចិត្ត ។

**២.៤.** បន្តវិធានការថែទាំសុខភាពអ្នកដែលបានចាកចេញពីគ្រឿងញៀន ព្រមទាំងបន្តពង្រឹងកិច្ចសហការរវាង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការជាដៃគូ ដើម្បីដោះស្រាយបញ្ហាគ្រឿងញៀន និងមេរោគអេដស៍ ជំងឺអេដស៍ ។

**២.៥.** បន្តពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីអនុវត្តតាមតួនាទី ភារកិច្ច បន្សាប ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម ចំពោះអ្នកចាកចេញពីគ្រឿងញៀនទៅកាន់គ្រួសារ និងសហគមន៍វិញ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖**

**៣.១.** បន្តចាត់វិធានការគ្រប់បែបយ៉ាងតាមផ្លូវច្បាប់ និងរដ្ឋបាល ដើម្បីប្រឆាំងការផលិត ការដាំដុះ ការចម្រាញ់ ការចរាចរជួញដូរ ការស្តុកទុក ការប្រើប្រាស់គ្រឿងញៀន និងទីតាំងសម្រួលឱ្យប្រើប្រាស់តាមគ្រប់រូបភាព។

**៣.២.** បន្តលើកកម្ពស់គុណភាពនៃការអនុវត្តច្បាប់ ដើម្បីបំផ្លាញអង្គការចាត់តាំង និងឧបាយកលថ្មីៗរបស់ឧក្រិដ្ឋជនគ្រឿងញៀន ដោយសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង និងអន្តរជាតិ ទប់ស្កាត់ការហូរចូលឱ្យបានជាអតិបរមានូវគ្រឿងញៀនគ្រប់ប្រភេទតាមតំបន់ព្រំដែន ជាពិសេសព្រំដែនកម្ពុជា-ឡាវ ។

**៣.៣.** បន្តពង្រឹងការយល់ដឹង សមត្ថភាព ឆន្ទៈ គុណធម៌ វិជ្ជាជីវៈ និងការទទួលខុសត្រូវនៃស្ថាប័នអនុវត្តច្បាប់ សំដៅបង្កើនគុណភាពនិងកាត់បន្ថយភាពអសកម្មនានា ដែលមិនស្មោះត្រង់ចំពោះវិជ្ជាជីវៈ និងការទទួលខុសត្រូវ ។

**៣.៤.** បន្តពង្រឹងការលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ក្នុងការកសាងសំណុំរឿង និងនីតិវិធីក្នុងការចោទប្រកាន់ ដើម្បីដាក់ទោសជនល្មើសឱ្យបានខ្លាំងក្លាថែមទៀត ស្របតាមខ្លឹមសារនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៣.៥.** បន្តជំរុញការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ពាក់ព័ន្ធនានា ដល់តំបន់គោលដៅងាយកើតមានបញ្ហាគ្រឿងញៀន ដូចជា ផ្ទះសំណាក់ ផ្ទះជួល សណ្ឋាគារ មណ្ឌលកម្សាន្តនានា ជាដើម ។

**៣.៦.** បន្តកិច្ចសហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រពង្រឹងប្រសិទ្ធភាពប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

**៤.១.** បន្តពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំ វត្ថុធាតុដើម ព្រមទាំងសារធាតុផ្សំផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ ការបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់។

**៤.២.** បន្តសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី រោងចក្រ សហគ្រាស ឱ្យមានការយល់ដឹងពីសារធាតុគីមីផ្សំដែលអាចបង្វែរយកទៅផលិតជាគ្រឿងញៀនខុសច្បាប់ ។

**៤.៣.** បន្តរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នៅតាមរាជធានី-ខេត្ត ស្តីពីការស៊ើបអង្កេត ការ

ចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនល្បចលាក់ ។

**៤.៤.** បន្តកិច្ចសហការប្រមូលព័ត៌មានពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

**៤.៥.** ជំរុញដំណើរការក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

**៤.៦.** សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំដែលនាំចូលស្របច្បាប់និងមិនស្របច្បាប់ ព្រមទាំងវត្ថុធាតុដើមឬសារធាតុញៀនផ្សេងទៀត ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

**៥.១.** ត្រៀមធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី១២ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដែលនឹងត្រូវធ្វើនៅខេត្តសៀមរាប ពីថ្ងៃទី០៣ ដល់ ០៦ ខែកញ្ញា ឆ្នាំ២០១៨ ។

**៥.២.** បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង តាមគ្រប់រូបភាពដោយផ្តោតសំខាន់លើការទប់ស្កាត់ការចរាចរគ្រឿងញៀន តាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ។

**៥.៣.** បន្តពង្រឹងយន្តការ និងពង្រីកការិយាល័យទំនាក់ទំនងព្រដែន (BLO) កម្ពុជា-ឡាវ / កម្ពុជា-ថៃ និង កម្ពុជា-វៀតណាម ។

**៥.៤.** បន្តការអនុវត្តគម្រោងមេគង្គក្រោម (Low Mekong) សម្រាប់ប្រទេសកម្ពុជា ថៃ និង ឡាវ ពីឆ្នាំ ២០១៧-២០១៨ ។

**៥.៥.** បន្តពង្រឹង និងពង្រីកយន្តការភូមិ ស គ្មានគ្រឿងញៀន នៅតាមបណ្តោយព្រំដែន កម្ពុជា-ថៃ និង កម្ពុជា-ឡាវ។

**៥.៦.** បន្តសហការជាមួយភាគីវៀតណាម ដើម្បីពន្លឿនការផ្តល់ថវិកាសាងសង់មជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តព្រះសីហនុ រួមនិងការលើកកម្ពស់កិច្ចសហប្រតិបត្តិការថ្មីៗបន្ថែមទៀតក្នុងក្របខ័ណ្ឌនៃការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**៥.៧.** បន្តអនុវត្តតាមអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី កម្ពុជា-ថៃ កម្ពុជា-ឡាវ កម្ពុជា-វៀតណាម ដែលបានឯកភាពគ្នាកន្លងមក ។

**៥.៨.** ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី កម្ពុជា ឡាវ វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖**

**៦.១.** ត្រៀមចូលរួមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន។

**៦.២.** ត្រៀមចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន លើកទី៣៩ ស្តីពីបញ្ហាគ្រឿងញៀន ។

**៦.៣.** ត្រៀមចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន លើកទី៦ ស្តីពីបញ្ហាគ្រឿងញៀន ។

**៦.៤.** ត្រៀមធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋាន (AAITF)។

**៦.៥.** ត្រៀមចូលរួមកិច្ចប្រជុំមន្ត្រីទំនាក់ទំនងប្រឆាំងគ្រឿងញៀន សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (ADLOMICO)។

**៦.៦.** បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីពង្រឹងនិងពង្រីកកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញារបស់អង្គការសហប្រជា

ជាតិ ស្តីពីគ្រឿងញៀន ។

**៦.៧.** បន្តបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន ពិសេសពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូជាតិ-អន្តរជាតិ ដើម្បីស្វែងរកមូលនិធិគាំទ្រលើការងារព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

**៦.៨.** បន្តកៀរគរបណ្តាប្រទេសផ្តល់ជំនួយនិងដៃគូអភិវឌ្ឍន៍នានា ពិសេសអង្គការ UNODC ដើម្បីគាំទ្រសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា តាមរយៈការអនុវត្តផែនការសកម្មភាពរបស់បណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ ។

**៦.៩.** បន្តការចូលរួមគ្រប់វេទិកាទាំងក្នុងតំបន់និងអន្តរជាតិ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់ការចរាចរ ជួញដូរគ្រឿងញៀន ។

**៦.១០.** បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-កូរ៉េ សំដៅពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់គ្រឿងញៀន និងគាំទ្រដល់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៦.១១.** បន្តចូលរួមអនុវត្តគម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Coordination Project) ឆ្នាំ២០១៦-២០១៨ ដែលគម្រោងនេះនឹងត្រូវបន្តសម្រាប់រយៈពេល៥ឆ្នាំទៀត (២០១៩-២០២៣) ជាផែនការប្រតិបត្តិការរួមគ្នាត្រួតពិនិត្យគ្រឿងញៀនសុវត្ថិភាពទន្លេមេគង្គ ។

**៦.១២.** បន្តចូលរួមអនុវត្តគម្រោងអនុតំបន់ តំបន់មួយចំនួន រួមមាន៖ គម្រោង PATROL, Container Control Program, AirCargo និង eLearning របស់អង្គការ UNODC Mekong Project របស់សាធារណរដ្ឋកូរ៉េ ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖**

**៧.១.** ត្រៀមរៀបចំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**៧.២.** ជំរុញនិងសម្របសម្រួលការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ ។

**៧.៣.** បន្តពង្រឹងស្ថាប័នសេនាធិការ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាជ្ញាធរពាក់ព័ន្ធទាំងអស់ ដើម្បីពង្រីកលទ្ធភាពអនុវត្តវិធានការយុទ្ធសាស្ត្រពហុវិស័យ របស់ អ.ជ.ប.គ.ញ. ឱ្យមានប្រសិទ្ធភាព ។

**៧.៤.** បន្តអនុវត្តអនុក្រឹត្យ និងបទដ្ឋានពាក់ព័ន្ធនឹងមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៧.៥.** បន្តការរៀបចំខ្លឹមសារសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៧.៦.** បន្តរៀបចំផែនការជាតិ ៥ ឆ្នាំ (២០១៩-២០២៣) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៧.៧.** បន្តអនុវត្តគោលនយោបាយលើកទឹកចិត្តដល់អង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមមាន ស្នាដៃលើការងារផ្សព្វផ្សាយអប់រំ ស្នាដៃការព្យាបាលនិងស្តារនីតិសម្បទា ស្នាដៃក្នុងការអនុវត្តច្បាប់ លើកទឹកចិត្តចំពោះអតីតអ្នកញៀនគ្រឿងញៀន ក្រុមគ្រួសារ និងសហគមន៍របស់គេ ។

**៧.៨.** បានបន្តការរៀបចំនីតិវិធីដាក់បញ្ចូលស្លឹករុក្ខជាតិខាត (KHAT) ទៅក្នុងតារាង ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ដែលតែងតែណែនាំ និងតម្រង់ទិសលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលបានដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១ លើកទី២ ទទួលបានជោគជ័យយ៉ាងធំធេង និងកំពុងដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ បន្តទៀត ប្រកបដោយការទទួលខុសត្រូវ មានការគាំទ្រ ការវាយតម្លៃខ្ពស់ពីសាធារណមតិជាតិ និងអន្តរជាតិ ក៏ដូចជាប្រជាពលរដ្ឋទូទៅ ។

សូមថ្លែងអំណរគុណផងដែរ ដល់គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងមន្ត្រីរាជការក្រោមឱវាទ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ វិស័យសាសនា បុគ្គលពាក់ព័ន្ធ ក៏ដូចជាសមាគមសង្គ្រោះនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការគាំទ្រ ការកសាងមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងនៅកន្លែងផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ សូមអរគុណចំពោះដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន សប្បុរសជន សិល្បករ ក៏ដូចជាប្រជាពលរដ្ឋ ដែលបានចូលរួមចំណែកជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការធ្វើឱ្យបានសម្រេចលទ្ធផលជាផ្លែផ្កាដូចមានក្នុងរបាយការណ៍ខាងលើ ។

សូមអំពាវនាវដល់គ្រប់សមាសភាពពាក់ព័ន្ធទាំងអស់ បន្តការគាំទ្រដល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីអនុវត្តកម្មវិធីការងារឱ្យកាន់តែទទួលបានលទ្ធផលជោគជ័យថ្មីៗបន្ថែមទៀត តាមទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញសម្រាប់អនុវត្តនៅក្នុង ឆមាសទី២ ឆ្នាំ២០១៨ ខាងមុខនេះ ។

**ឧបនាយករដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ចម្លងជូន** :

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.

" ដើម្បីជូនជ្រាប "

-ក្រសួងសមាជិក អ.ជ.ប.គ.ញ.

-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ.

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត

-នាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីមុខការ "

-ឯកសារ-កាលប្បវត្តិ